# វិសាខបូជា

**វិសាខបូជា** គឺជាពិធីបូជាធំ វិសេសវិសាល និងមានសារៈសំខាន់បំផុតមួយសម្រាប់ពុទ្ធសាសនិកទាំងឡាយក្នុងសកលលោកនេះ។ វិសាខបូជា គឺជាពុទ្ធានុស្សរណរំលឹកដល់ព្រះពុទ្ធគោត្តមនៅថ្ងៃ១៥កើត ពេញបូណ៌មី ខែពិសាខ ហើយកំណត់ឲ្យឈ្មោះថាវិសាខបូជា។ ពិធីបុណ្យវិសាខបូជា បានកំណត់ទុកក្នុងគម្ពីរបឋមសម្ពោធិ ថាជាមហាមង្គលអភិលក្ខិតកាល គឺមានន័យថា ជាថ្ងៃមហាមង្គលរបស់ព្រះសមាសម្ពុទ្ធព្រះបរមគ្រូទ្រង់៖

១ ព្រះអង្គប្រសូតចាកព្រះមាតុទរ

២ ព្រះអង្គទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ

៣ ព្រះអង្គទ្រង់រំលត់ក្ខន្ធចូលកាន់ព្រះបរមនិព្វាន[៦]

ព្រឹត្តិការណ៍ទាំងបីយ៉ាងនេះ គឺ ប្រសូត ត្រាស់ដឹង និងចូលបរិនិព្វាន គឺសុទ្ធតែត្រូវនៅក្នុងថ្ងៃពេញបូណ៌មីខែពិសាខទាំងអស់ លើកលែងតែឆ្នាំប៉ុណ្ណោះដែលមិនត្រូវគ្នា (រូបលេខ១-៣)។

វេលានៃការប្រារព្ធពិធីវិសាខបូជា ក្នុងប្រទេសកាន់ព្រះពុទ្ធសាសនាណាៗក្តី ក៏នឹងត្រូវប្រព្រឹត្តិទៅនៅវេលាយប់ទាំងអស់ ដែលទាំងនេះគឺជាប់ពាក់ព័ន្ធនឹងពីរករណី៖ ទីមួយគឺតម្រូវទៅលើវេលាដែលព្រះច័ន្ទពេញបូណ៌មី និងទីពីរគឺទាក់ទងនឹងការអុជប្រទីបផ្កាលាបូជាឲ្យភ្លឺរុងរឿងឡើង ហើយក៏ដើម្បីឲ្យពុទ្ធសាសនិកបានជួបជុំគ្នាត្បិតជាវេលាយប់ដែលមានពេលទំនេរ។ ពិធីបុណ្យក្នុងព្រះពុទ្ធសាសនា គឺមានសារៈសំខាន់ណាស់សម្រាប់ពុទ្ធសាសនិកប្រុសស្រីចាស់ក្មេងទាំងឡាយ។ ប៉ុន្តែរឹតតែវិសេសវិសាលជាងនេះ ពុទ្ធសាសនិកទាំងចាស់ក្មេងបានឲ្យសារៈសំខាន់នឹងភាពចាំបាច់ចំពោះពិធីបុណ្យវិសាខបូជា។ គេបាននាំគ្រឿងសក្ការៈបូជាទាំងឡាយ ពិសេសមាន ផ្កាភ្ញី និងប្រទីបផ្កាលាធំ តូច ហើយអុជបំភ្លឺព្រោងព្រាត ដែលជាទូទៅធ្វើឡើងក្នុងអារាមនានា (រូបលេខ៤)។

តាមគន្លងប្រពៃណីដែលត្រឹមត្រូវ ការប្រារព្ធពិធីបុណ្យវិសាខបូជា គឺត្រូវមានការសំដែងខ្សែរឿងពុទ្ធប្រវត្តិតាំងអំពីដើមរហូតដល់ចប់។ ការសូត្រសំដែងនេះ គឺដើម្បីជាគ្រឿងបណ្តុះសទ្ធាដល់ពុទ្ធបរិស័ទឲ្យកើតមានក្នុងគុណព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃឲ្យបានខ្លាំងក្លារឹងមាំឡើង។ ដោយឡែកសម្រាប់គ្រឿងផ្សេងៗដែលជាអមិសបូជា ឬជផ្ទាយ

---

[៦] Kariyawasam A. G. S, *Buddhist Ceremonies and Rituals of Sri Lanka*, 15.

ដែលជាគ្រឿងទាក់ចិត្តទាំងឡាយដូចជាទេយ្យទាន និងអាហារជាដើមក្តី គ្មានមានសំខាន់ឬភាពចាំបាច់ឡើយក្នុងកិច្ចពិធិនេះ (រូបលេខ៥)។

ពិធីបុណ្យវិសាខបូជាក៏មានប្រារព្ធជាពិសេសក្នុងព្រះបរមរាជវាំងដែរ ពីព្រោះជាព្រះរាជកុសលផ្ទាល់របស់ព្រះអង្គ។ ក្នុងព្រះរាជវាំងមានរៀបចំតាំងព្រះពុទ្ធរូប ហើយព្រះមហាក្សត្រព្រះអង្គ បានតាំងគ្រឿងដង្វាយដែលជាព្រះរាជទ្រព្យផ្ទាល់របស់ទ្រង់ ដែលមានដូចជាផ្កាស្រស់ជាច្រើនគូ ទៀនធំលាបទឹកមាស១គូ ទៀនតូចៗជាច្រើន និងប្រទីបផ្កាលាភ្លឺព្រោងព្រាត។[២] ក្នុងវេលាម៉ោង៧យប់ ព្រះរាជាយាងទៅអុជទៀនធូប និងធ្វើបទមនស្សការព្រះរតនត្រ័យ និងទ្រង់ធ្វើកិច្ចសំដែងសុំខមាទោសកំហុសនៅចំពោះព្រះភក្តិរបស់ព្រះពុទ្ធបដិមា។ លំដាប់បន្ទាប់មក មានព្រះសង្ឃសំដែងធម្មទេសនា ជាពិសេសអំពីជាតិត្រកូលដូចជា រឿងការប្រសូតរបស់ព្រះសមាសម្ពុទ្ធ រឿងមានព្រះទេពី រឿងគ្រប់គ្រងរាជ្យ រឿងស្តេចចេញទ្រង់ផ្នួស រឿងត្រាស់ជាព្រះពុទ្ធ ព្រះអង្គទ្រង់បំពេញពុទ្ធកិច្ច និងព្រះអង្គរំលត់ខន្ធចូលទៅកាន់ព្រះបរមនិព្វានជាបង្ហើយធម្មទេសនា។[៣]

គួរឲ្យកត់សម្គាល់ថាទំនៀមការប្រារព្ធពិធីបុណ្យវិសាខបូជា គឺមានតាំងពីបុរាណកាលមក គឺមានបន្ទាប់ពីព្រះពុទ្ធចូលកាន់ព្រះមហាបរិនិព្វាជាច្រើនរយឆ្នាំ[៤] ហើយប្រទេសដែលបានប្រារព្ធពិធីនេះដំបូងគេគឺទំនងជាប្រទេសឥណ្ឌា។ ប៉ុន្តែលុះក្រោយមកនៅពេលដែលសាសនានេះ បានទទួលយកមកប្រតិបត្តិដោយប្រទេសជាច្រើនហូរហែរមក ទើបប្រទេសទាំងនោះ ក៏មានប្រារព្ធពិធីបុណ្យរំលឹកដល់ព្រឹត្តិការណ៍ដ៏សំខាន់ទាំងបីរបស់ព្រះសម្មាសម្ពុទ្ធជាទូទៅរៀងរាល់ឆ្នាំតរាបរៀងមក។

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION

[២] ពុទ្ធសាសនបណ្ឌិត្យ ១៩៥១:៥៩

[៣] Ibit ១៩៥១:៦១

[៤] Ibit ១៩៥១:៦២

អត្ថបទដោយ៖ មាស សុភាព

# បញ្ជីរូបភាព



រូបលេខ១៖ កំណើតព្រះពុទ្ធ ( ចម្លាក់នៅសារមន្ទីរអង់គ្លេស)



រូបលេខ២៖ ឆព្ណណរង្សី បញ្ជាក់ការត្រាស់ដឹង



រូបលេខ៣៖ បដិមាព្រះពុទ្ធចូលបរិនិព្វាន (រូបកណ្តាល ខាងមុខ)

អត្ថបទដោយ៖ មាស សុភាព



រូបលេខ៤៖ ពិធីបង្ហោះគោម និងអុជប្រទីបផ្កាលា ថ្វាយពិធីវិសាខបូជា



រូបលេខ៥៖ ពិធីបុណ្យវិសាខបូជា និងការស្តាប់ព្រះធម៌ទេសនា

អត្ថបទដោយ៖ មាស សុភាព

## ឯកសារយោង

ជួន ណាត

១៩៦៧-១៩៦៨, *វចនានុក្រមខ្មែរ ភាគ១-២*, ភ្នំពេញ

ពុទ្ធសាសនបណ្ឌិត្យ

១៩៥១, *ព្រះរាជពិធីទ្វាទសមាស ភាគទី១ ទី២ ទី៣*, ភ្នំពេញ

Kariyawasam A.G.S.

1995, *Buddhist Ceremonies and Rituals of Sri Lanka.* Kandy: Buddhist Publication Society.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION